ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សក
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៤៧ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

## ប្រកាស
## ស្តីពី
## ការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍
## ដើម្បីអោយបានឈប់សំរាកបន្ថែមនារសៀលថ្ងៃសៅរ៍

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ដើម្បីអោយបានឈប់សំរាកនារសៀលថ្ងៃសៅរ៍ បន្ថែមលើការឈប់សំរាកប្រចាំសប្តាហ៍ជាធម្មតានៅថ្ងៃអាទិត្យ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ អាចរៀបចំអោយកម្មករនិយោជិតធ្វើការតែប្រាំថ្ងៃកន្លះក្នុងមួយសប្តាហ៍ ។ ក្នុងករណីនេះ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចបង្កើនថិរវេលាធ្វើការពេញលេញរបស់កម្មករនិយោជិតដល់ប្រាំបួនម៉ោងជាអតិបរមាក្នុងមួយថ្ងៃ ។

**ប្រការ២.-** ក្នុងការបែងចែកម៉ោងធ្វើការថ្មីនេះ បើការងារក្នុងសហគ្រាស គ្រឹះស្ថានបានរៀបចំឡើងជាពីរវេនបន្តបន្ទាប់គ្នា វេនទីមួយត្រូវបានសំរាកបន្ថែមនារសៀលថ្ងៃសៅរ៍ ហើយវេនទីពីរត្រូវបានសំរាកបន្ថែមនាព្រឹកថ្ងៃចន្ទ័នៃសប្តាហ៍បន្ទាប់ ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានបំណងបែងចែកម៉ោងធ្វើការរបៀបខាងលើ ត្រូវមានការឯកភាពជាមុន ជាមួយសហជីពដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬជាមួយចំនួនពាក់កណ្តាល នៃកម្មករនិយោជិតតាមរយៈការបោះឆ្នោតជាសំងាត់ បើសហគ្រាស គ្រឹះស្ថានគ្មានប្រតិភូបុគ្គលិក និងសហជីព ។

**ប្រការ៤.-** បើមានការឯកភាពជាមួយ សហជីពដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬកម្មករនិយោជិតរួចហើយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចអនុវត្តម៉ោងធ្វើការថ្មីមួយថ្ងៃបន្ទាប់ពីបានបិទផ្សព្វផ្សាយការបែងចែកម៉ោងធ្វើការថ្មីនេះនៅក្នុង សហគ្រាស គ្រឹះស្ថាន ។ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសិន ជាសហគ្រាស គ្រឹះស្ថាននោះ ស្ថិតនៅរាជធានីភ្នំពេញនៅមុនពេលអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៩ សកអ. ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ